**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

•••••••••••••••••••

# របាយការណ៍
# នៃកិច្ចប្រជុំថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៣ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមួយ ក្រោមអធិបតីភាព **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី ទទួលបេសកកម្មពិសេស និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមាន៖ ឯកឧត្តម លោកជំទាវ ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម លោក លោកស្រីជាអគ្គលេខាធិការ អគ្គលេខាធិការរង និង ជាប្រធាននាយកដ្ឋានទាំងអស់ ។

**អវត្តមាន**

1. ឯកឧត្តមវេជ្ជ. ម៉ម ប៊ុនហេង អនុប្រធានទី១
2. លោកជំទាវ ស៊ឹម ខេងខាំ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
3. ឯកឧត្តម ឡឹម ពេជ្ជពិសី ទីប្រឹក្សា

គោលបំណងនៃកិច្ចប្រជុំនេះមាន៖

- របាយការណ៍សកម្មភាព ដែលបានអនុវត្តពីខែ តុលា ដល់ ខែធ្នូ ឆ្នាំ ២០១៣
- វឌ្ឍនភាព ក្នុងការរៀបចំផែនការគោល (Master Plan ) សំរាប់អនុវត្ត
- គោលនយោបាយ ៧ ចំណុច ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានមានប្រសាសន៍ស្វាគមន៍ ដល់ថ្នាក់ដឹកនាំ និង មន្ត្រីទាំងអស់ ដោយបានបញ្ជាក់ពីទឹកចិត្ត ក្នុងនាមជាប្រធានដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ការតាំងចិត្តដើម្បីដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឲ្យដំណើរការទៅបានប្រសើរ និង មានប្រសិទ្ធភាព ។

ឯកឧត្តម បានបញ្ជាក់ពីកិច្ចការជាច្រើននៅចំពោះមុខ ដែលត្រូវធ្វើ និងផ្តល់ឱកាសជូនសមាជិកអង្គប្រជុំ ក្នុងការផ្តល់មតិ ដើម្បីជាជំនួយក្នុងការដឹកនាំ ។ ជាមួយគ្នានេះដែរ ឯកឧត្តម ក៏បានណែនាំពីរបៀបរបបនៃកិច្ចប្រជុំ មានដូចតទៅ៖

1. នៅក្នុងកិច្ចប្រជុំ សមាជិកទាំងអស់ ត្រូវគោរពគ្នាទៅវិញទៅមក ក្នុងពេលប្រជុំ
2. សមាជិកចូលរួមប្រជុំ ត្រូវស្លៀកបំពាក់ឲ្យបានសមរម្យ (អាវធំ )

3. អគ្គលេខាធិការដ្ឋាន ត្រូវចាត់ចែងអ្នកកត់ត្រា ដើម្បីធ្វើរបាយការណ៍ និង បញ្ចប់នៅថ្ងៃបន្ទាប់
4. ឯកឧត្តមវេជ្ជ ហោ ប៊ុនឡេង ដែលជាប្រធានគណៈកម្មាធិការត្រួតពិនិត្យគេហទំព័រ ត្រូវចេញជាពីរភាសា ខ្មែរ និង អង់គ្លេសឲ្យបានលឿនបំផុត ។
5. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវលើការរៀបចំប្រជុំ ដើម្បីឲ្យដំណើរការបានល្អប្រសើរ ។

**១-បាយការណ៍សកម្មភាព ដែលបានអនុវត្តពីខែ តុលា ដល់ ខែធ្នូ ឆ្នាំ ២០១៣ (បង្ហាញដោយឯកឧត្តមអគ្គលេខាធិការ** ) ៖

**ក.១- សកម្មភាពទូទៅ**

- រៀបចំកិច្ចប្រជុំ សម្របសម្រួល រវាងឯកឧត្តមទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយ មូលនិធិសកល នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៣ អង្គការសង្គមស៊ីវិល និង UN Team នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៣ ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានដឹកនាំគណៈប្រតិភូកម្ពុជាចំនួន ៨០រូប ចូលរួបប្រជុំ ICAAP នាថ្ងៃទី១៨-២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។
- កិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ(PB) ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដែលក្នុងនោះបានផ្តោតទៅលើប្រធានបទចំនួន ៣ គឺ New Funding Model Investment Framework និង Preparing the Policy ។
- ប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូ ឆ្នាំ ២០១៣ ដែលផ្តោតទៅលើប្រធានបទដំណើរឆ្ពោះទៅសម្រេចគោលដៅ សូន្យបី ។
- ប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តក្រចេះ ដែលលទ្ធផល បានរកឃើញបញ្ហាខ្វះស្បៀងសំរាប់អ្នករស់នៅជាមួយមេរោគអេដស៍ និង ជំងឺអេដស៍ និង អ្នករស់នៅជាមួយមេរោគអេដស៍ និង ជំងឺអេដស៍ មានការចល័តពីកន្លែងមួយ ទៅកន្លែងមួយផ្សេងទៀត ។
- កិច្ចប្រជុំជាន់ខ្ពស់ ស្តីពីការអនុវត្តបទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និង ស្រីស្រស់ ដែលក្នុងនោះ បានផ្តោតទៅលើ ការកាត់បន្ថយការរើសអើង និង មាក់ងាយ និង ពង្រឹងកិច្ចសហការ ក្នុងការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ។

**ក.២-សកម្មភាពរបស់នាយកដ្ឋាន**

- នាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន បានសម្របសម្រួលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ នៅខេត្តកែប ថ្ងៃទី ០៧-០៨ ខែតុលា ឆ្នាំ ២០១៣ និង ខេត្តកំពតនៅថ្ងៃខទី ៣០-៣១ ខែតុលា ឆ្នាំ ២០១៣ ។

- នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ បានសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល M&E នៅខេត្តព្រះសីហនុ ថ្ងៃទី ៣០-៣១ ខែតុលា ឆ្នាំ ២០១៣ ។
- នាយកដ្ឋានបង្ការ ថែទាំ និង គាំទ្រ បានសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល MCPI ចំនួន ០៣ នៅខេត្តកំពង់ឆ្នាំង ថ្ងៃទី១៦-១៧ ខែតុលា និង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១៣ ខេត្តសៀមរាប ថ្ងៃទី ៣០-៣១ ខែតុលា ឆ្នាំ ២០១៣ និង ខេត្តពោធិសាត់ ថ្ងៃទី ០៦-០៧ ខែវិច្ឆិការ ឆ្នាំ ២០១៣ ។

ចំពោះសកម្មភាព ដែលបានអនុវត្តនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ ជាមួយនឹងការកោតសសើរ ដូចតទៅ ៖

- ចូលរួមប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅតាមខេត្ត ត្រូវមានផែនការ និង ពេលវេលាច្បាស់លាស់ ដើម្បីឲ្យបេសកកម្មនេះ មានដំណើរការទៅដោយរលូន ។
- ត្រូវបង្កើនការទទួលខុសត្រូវ ចំពោះការអនុវត្តការងារ (ឧទាហរណ៍ការរៀបចំប្រគុំតន្ត្រី ដើម្បីផ្សព្វផ្សាយអេដស៍ នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០១៣ គ្មានមន្ត្រីទទួលខុសត្រូវប្រចាំការមើល ) ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវបង្កើនទំនុកចិត្តពីថ្នាក់ដឹកនាំ ក្នុងនាមជាសេនាធិការ ។
- រាល់ការចំណាយថវិកាមូលនិធិសកល ត្រូវរៀបចំនិតិវិធី ដូចការចំណាយថវិកាជាតិដែរ ចាប់ពីឆ្នាំ ២០១៤ ទៅ ។
- ចំពោះគម្រោងលទ្ធកម្មសំរាប់ឆ្នាំខាងមុខ អគ្គលេខាធិការ និង នាយកដ្ឋានពាក់ព័ន្ធ ត្រូវជួបប្រជុំជាមួយខ្ញុំ នៅសប្តាហ៍ក្រោយ ដើម្បីពិភាក្សាការងារនេះ ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវរៀបចំជួសជុល និង កែលំអឡើងវិញ នូវអាគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាំងពីកន្លែងចតរថយន្ត ខាងមុខអាគារ ។ល ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវរៀបចំឡើងវិញ នូវការទុកដាក់សំភារៈនៅក្នុងឃ្លាំង ត្រូវរៀបចំទៅតាមលក្ខណៈបច្ចេកទេស និង មានរបៀបរាបរយ ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ បុគ្គលិក ពិនិត្យមើលមន្ត្រីមកធ្វើការ និង មន្ត្រីមិនសូវមកធ្វើការ ។ មន្ត្រីមកធ្វើការ ត្រូវមានការលើកទឹកចិត្ត ដូចជាតម្លើងឋានៈ និង កាំប្រាក់ជាដើម ។

**២-វឌ្ឍនភាព ក្នុងការរៀបចំផែនការគោល (Master Plan ) សំរាប់អនុវត្ត (បង្ហាញដោយ ឯកឧត្តមវេជ្ជទា ផលា ) ៖**

ក្នុងនោះ បានផ្តោតទៅលើចំណុចសារជាគន្លឹះចំនួន ០៩ សំខាន់ៗ ដូចជា៖

1. ពង្រឹងមគ្គុទេសភាព និង ការគ្រប់គ្រង
2. វិនិយោគដោយភាពវៃឆ្លាត
3. ទិន្នន័យ គឺជាអំណាច
4. រូបអ្នកនេះហើយ គឺជាអ្នកដឹកនាំ

5. សូមទុកសហគមន៍ ជាស្នូលនៃការឆ្លើយតប
6. ឈប់ធ្វើដូចពីមុនទៀត ត្រូវធ្វើតាមរបកគំហើញថ្មី
7. ជំរុញការស្វែងរកករណីថ្មី បង្កើនអ្នកប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ និង ធ្វើឲ្យគាត់បន្តការព្យាបាលជាប់ជាប្រចាំ ។
8. ផ្តោតលើប្រជាជន ចំណុច និង ទីតាំងភូមិសាស្ត្រ
9. លុបបំបាត់ការរើសអើង និង មាក់ងាយ

ឯកឧត្តម មានប្រសាសន៍ទៀតថា ដើម្បីសម្រេចបាននូវគោលដៅសូន្យបី នោះយើងត្រូវអនុវត្តនូវក្រុមការងារនេះ

- Continuum of Prevention, Care, Treatment and Support
- Impact Mitigation
- Enabling Environment and HR
- Leadership and Development Synergies

## ៣-នយោបាយ ៧ ចំណុច ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល (បង្ហាញដោយ ឯកឧត្តមវេជ្ជ ទា ផលា )៖

ជាអនុសាសន៍ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានមានប្រសាសន៍ថា ដោយសារការងារនេះ ជាការងារបច្ចេកទេស ដូចនេះទុកឲ្យក្រុមការងារបច្ចេកទេសប្រជុំពិភាក្សាគ្នាជាក្រោយ ។ ជាដំបូងនេះ ឯកឧត្តមក៏បានធ្វើការបែងចែកជូនឯកឧត្តម លោកជំទាវ ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលខុសត្រូវក្នុងការសម្រសម្រួលជា មួយស្ថាប័នពាក់ព័ន្ធ លើការងារអេដស៍ មាន៖

1. ឯកឧត្តមវេជ្ជ. អ៊ឹង វុទ្ធី ទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល លើការងារប្រើប្រាស់ស្រោមអនាម័យ ១០០% ។
2. ឯកឧត្តមវេជ្ជ. ស៊ឹម គឹមសែន ទទួលខុសត្រូវក្នុងការសម្របសម្រួលលើការងារគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ។
3. ឯកឧត្តមវេជ្ជ. ជា សំអាន ទទួលខុសត្រូវក្នុងការសម្របសម្រួលលើការងាររៀបចំផែនទីបញ្ជាក់ពីភូមិសាស្ត្រចំនួនអ្នកផ្ទុកមេរោគអេដស៍ ។
4. ឯកឧត្តម លោកជំទាវទាំងអស់ ទទួលខុសត្រូវក្នុងការសម្របសម្រួលគណៈកម្មាធិការប្រុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់ ឲ្យមានសកម្មភាពឡើងវិញ ។ ដោយឡែកជាមួយមន្ទីរសុខាភិបាលរាជធានី ខេត្តនីមួយៗ ឯកឧត្តមប្រធាន នឹងស្នើឲ្យឯកឧត្តមវេជ្ជ. ម៉ម ប៊ុនហេង ជួយសម្របសម្រួល ។
5. ឯកឧត្តមវេជ្ជ. កៅ ទ្រី ទទួលខុសត្រូវក្នុងការសម្របសម្រួលលើការងារគ្រឿងញៀន
6. ឯកឧត្តមវេជ្ជ. តែង គន្ធី ទទួលខុសត្រូវក្នុងការសម្របសម្រួលលើការងារយុវជន

7. ឯកឧត្តមវេជ្ជ. ទា ផលា ទទួលខុសត្រូវក្នុងការសម្របសម្រួលលើការតាមដានអនុវត្តការងារឆ្លើតតបមេរោគអេដស៍ ។

**ការពិភាក្សា**

- **ឯកឧត្តមវេជ្ជ អ៊ឹង វុទ្ធី** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានលើកឡើងថា អគ្គលេខាធិការដ្ឋាន ពិសេសលទ្ធផលសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ សូមរាយការណ៍ជូនថ្នាក់ដឹកនាំ បានដឹងផង ។ កន្លងមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គ្មានតំលៃទេ ដើម្បីឲ្យអាជ្ញាធរមានតំលៃឡើងវិញ ត្រូវពង្រឹងផ្ទៃក្នុងខ្លួនឯង និង ពង្រឹងក្រុមប្រឹក្សាបច្ចេកទេស ។

- **ឯកឧត្តមវេជ្ជ ស៊ឹម គឹមសែន** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានលើកឡើងថា ធ្វើដូចម្តេច គ្រប់គ្រងថវិកា ៤២លានដុល្លាឲ្យបាន ។

- **ឯកឧត្តមវេជ្ជ ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានឆ្លើយតប និង បញ្ជាក់ទៅលើមតិរបស់ឯកឧត្តមវេជ្ជ ស៊ឹម គឹមសែន ដើម្បីគ្រប់គ្រងថវិកា ៤២ លានដុល្លានេះបាន ត្រូវសុំទៅស្ថាប័នពាក់ព័ន្ធ ប្រមូលថវិកាមកដាក់ជាកញ្ចប់ទៅតាមក្រុមការងារនីមួយៗដែលត្រូវធ្វើ ។

**៤-ការតាក់តែងឡើងវិញនូវគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (បង្ហាញដោយ ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង)៖**

ដែលក្នុងនោះបានរៀបចំជា ៤ ចំណុចសំខាន់ៗ មាន៖

1. សារតា
2. សមាសភាពគន្លឹះ នៃគេហទំព័រថ្មី
3. សមាសភាពដោយឡែក នៃសមាសភាពគន្លឹះនីមួយៗ
4. កិច្ចខិតខំប្រឹងប្រែងបន្ត

ក្រោយពីបង្ហាញមក ឯកឧត្តមប្រធាន បានមានប្រសាសន៍ទៅលើការកែលំអ មានដូចតទៅ៖

1. ពិនិត្យមើលឲ្យបានម៉ត់ចត់ ទៅលើការសរសេរអក្ខរាវិរុទ្ធ នៅក្នុងគេហទំព័រ
2. សរសេរឈ្មោះឲ្យបានត្រឹមត្រូវ
3. កាលបរិច្ឆេទជាភាសាអង់គ្លេស ត្រូវសរសេរខែមុន បន្ទាប់មកថ្ងៃ និង ឆ្នាំ
4. ព័ត៌មាន ត្រូវដាក់ពីរ ( បើព័ត៌មានមិនទាន់ផ្លូវការទេ(Up Coming News) ត្រូវដាក់ឲ្យរត់ ហើយបើផ្លូវការ(Update News) ត្រូវ Post ។

ចុងបញ្ចប់ ឯកឧត្តមប្រធាន បានបញ្ចប់នូវកិច្ចប្រជុំ នៅវេលាម៉ោង ១១:០០នាទី នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាស សាមគ្គីភាព និង ទទួលខុសត្រូវខ្ពស់។

ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**ឯកឧត្តមបណ្ឌិត តែង គន្ធី**